# ជំពូកទី ១៦

## ពិការភាព និងតម្រូវការការអប់រំពិសេស

### គោលបំណងមេរៀន

អ្នកសិក្សានឹងអាចយល់ និងពន្យល់អំពីៈ

- និយមន័យនៃជំងឺ ភាពចុះខ្សោយនៃរាងកាយ ពិការភាព និងជនពិការដោយប្រើឧទាហរណ៍ជាក់លាក់
- គំរូវេជ្ជសាស្ត្រនៃពិការភាព គំរូសង្គមនៃពិការភាព និងគំរូសមាហរណកម្មនៃពិការភាព (ការចាត់ថ្នាក់ជាអន្តរជាតិលើការបំពេញមុខងារ ពិការភាព និងសុខភាព (International Classification of Functioning, Disability and Health) ហៅកាត់ថា អាយ ស៊ី អេហ្វ (ICF)
- បញ្ហាប្រឈមនានាក្នុងការអប់រំកុមារមានពិការភាពនៅកម្ពុជា

ជំពូកនេះផ្តល់ចំណេះដឹងជាមូលដ្ឋានចាំបាច់ក្នុងការយល់ដឹងអំពីជំងឺ ភាពចុះខ្សោយនៃរាងកាយ ពិការភាព និងជនពិការ។ បន្ទាប់មក ក្នុងជំពូកនេះក៏មានពន្យល់អំពីគំរូវេជ្ជសាស្ត្រនៃពិការភាព គំរូសង្គមនៃភាពពិការភាព និងការចាត់ថ្នាក់ជាអន្តរជាតិលើការបំពេញមុខងារ ពិការភាព និងសុខភាព ដែលជាគំរូសមាហរកម្មនៃពិការភាព (ICF)។ ចុងក្រោយ យើងរៀបរាប់អំពីស្ថានភាពបច្ចុប្បន្ននៃតម្រូវការអប់រំពិសេសសម្រាប់កុមារមានពិការភាពនៅប្រទេសកម្ពុជាផងដែរ។

សូមកត់សម្គាល់ថា នៅក្នុងជំពូកនេះសុខភាពត្រូវបានចាត់ទុកជាកត្តាមួយនៃពិការភាពពោលគឺ នៅក្នុងលក្ខខណ្ឌសុខភាពដូចជា ជំងឺ ឬការរងរបួសផងដែរ។ និយមន័យនេះមានន័យខុសគ្នាពីអត្ថន័យទូលំទូលាយដែលបានលើកឡើងចំពោះសុខភាពនៅក្នុងជំពូកមុន (ឧទាហរណ៍ **ជំពូកទី ១**)។

## ១ និដ្ឋភាពផ្សេងៗនៃជំងឺ ភាពចុះខ្សោយនៃរាងកាយ ពិការភាព និងជនពិការ

### ១.១. ជំងឺ

**ជំងឺ**បណ្តាលមកពីភាពមិនប្រក្រតីនៅគ្រប់ផ្នែក ឬផ្នែកណាមួយនៃសរីរាង្គកាយរបស់ភាវៈរស់មានជីវិត។ បុគ្គលដែលមានជំងឺគឺមិនអាចបំពេញមុខងារនានាជាធម្មតាបានទេ ហើយជាទូទៅជួបប្រទះនូវការឈឺចាប់តាមប្រភេទផ្សេងៗគ្នា។ ទោះជាយ៉ាងណាក៏ដោយ ជំងឺមួយចំនួនដូចជាជំងឺទឹកនោមផ្អែមមិនបង្កឱ្យមានអារម្មណ៍ឈឺចាប់មុននឹងឈានដល់ដំណាក់កាលធ្ងន់ធ្ងរទេ។ <u>ជំងឺត្រូវបានគេកំណត់និយមន័យថាជាលក្ខខណ្ឌមួយដែលកោសិកាទទួលរងការខូចខាតដោយសារមូលហេតុណាមួយ និងមិនអាចដំណើរការល្អដូចធម្មតាបាន</u>។

ជំងឺដែលបណ្តាលមកពីភាពមិនប្រក្រតីផ្នែករូបសាស្ត្រនៅក្នុងកោសិកាហៅថា «**ជំងឺសរីរាង្គ (Organic Diseases)**»។ ជំងឺទាំងនេះផ្ទុយនឹង «**ជំងឺពាក់ព័ន្ធនឹងការបំពេញមុខងារ (Functional Diseases)**» ដែលចំណេះដឹងផ្នែកវេជ្ជសាស្ត្របច្ចុប្បន្នមិនទាន់អាចកំណត់បានពីភាពមិនប្រក្រតីនៃកោសិកានៅឡើយ។ ជំងឺមហារីក ជំងឺទឹកនោមផ្អែម ជំងឺសរសៃឈាមខួរក្បាល និងជំងឺបេះដូងត្រូវបានគេចាត់ទុកថាជាជំងឺសរីរាង្គ ផ្ទុយទៅវិញជំងឺផ្លូវចិត្តត្រូវបានគេចាត់ចូលក្នុងប្រភេទជំងឺដែលពាក់ព័ន្ធនឹងការបំពេញមុខងារ។

### ១.២. ភាពចុះខ្សោយនៃរាងកាយ ពិការភាព និងជនពិការ

#### ១.២.១. និយមន័យនៃភាពចុះខ្សោយនៃរាងកាយ ពិការភាព និងជនពិការ

អង្គការសុខភាពពិភពលោក WHO (ឆ្នាំ១៩៨០) បានផ្តល់និយមន័យនៃភាពចុះខ្សោយនៃរាងកាយ ពិការភាព និងជនពិការដូចតទៅ៖[1,2,3] **ភាពចុះខ្សោយនៃរាងកាយ**គឺជាដំណើរការមិនប្រក្រតីរបស់រាងកាយ ឬផ្លូវចិត្តដែលអាចមានជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នដោយសារការបាត់បង់រចនាសម្ព័ន្ធ ឬមុខងារណាមួយនៃផ្លូវចិត្ត ឬរាងកាយ។ ទន្ទឹមនឹងនេះ **ពិការភាព**គឺជាការរឹតត្បិត ឬកង្វះសមត្ថភាព (បណ្តាលមកពីភាពចុះខ្សោយ) ក្នុងការអនុវត្តសកម្មភាពអ្វីមួយតាមលក្ខណៈ ឬក្នុងជួរដែលចាត់ទុកថាជារឿងធម្មតាសម្រាប់មនុស្សទូទៅ។ **ជនពិការ**គឺជាគុណវិបត្តិរបស់បុគ្គលដែលកំណត់ ឬរារាំងដល់ការបំពេញតួនាទីដែលមានលក្ខណៈធម្មតា។

ទោះជាយ៉ាងណាក៏ដោយ ទស្សនៈស្តីពីពិការភាពមានភាពស្មុគស្មាញ ហើយអាចត្រូវបានបែងចែកជាគំរូមូលដ្ឋានពីរគឺ **គំរូវេជ្ជសាស្ត្រ** និង**គំរូសង្គម**។

## ២ គំរូនៃពិការភាព

### ២.១. គំរូវេជ្ជសាស្ត្រនៃពិការភាព

នៅក្នុង**គំរូវេជ្ជសាស្ត្រ** ពិការភាពត្រូវបានកំណត់ជាលក្ខខណ្ឌដែលរាងកាយមិនបានដំណើរការធម្មតាដោយសារជំងឺ ឬរបួស (**រូបទី ១៦.១**)។ នេះបណ្តាលឱ្យមានការថយចុះនូវសមត្ថភាពចាំបាច់សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃដែលធ្វើឱ្យបុគ្គលទាំងនោះតែងតែចាញ់ប្រៀបគេនៅក្នុងសង្គម។ ឧទាហរណ៍ គ្រោះថ្នាក់នៃជំងឺដាច់សរសៃឈាមខួរក្បាលអាចបណ្តាលឱ្យខូចខួរក្បាល (ជំងឺ) ដែលធ្វើឱ្យប៉ះពាល់ដល់មុខងារជាច្រើននៃរាងកាយជារៀងរហូត។ វារួមបញ្ចូលទាំងការស្ពឹកដៃនិងជើង ភាពមិនប្រក្រតីក្នុងការនិយាយ និងបញ្ហាផ្សេងៗទៀត (ភាពចុះខ្សោយនៃរាងកាយ)។ ការស្ពឹកដៃ និងជើងអាចជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការបន្លាស់ទី សមត្ថភាពចាប់កាន់វត្ថុ និងជំនាញជីវិតប្រចាំថ្ងៃផ្សេងទៀត (ពិការភាព)។ ជនរងគ្រោះអាចបាត់បង់សមត្ថភាពក្នុងការបំពេញការងារ ធ្វើការងារផ្ទះ និងការបំពេញតួនាទីសង្គមផ្សេងៗទៀត (ជនដែលទទួលរងគុណវិបត្តិសង្គម ឬជនពិការ)។




**រូបទី ១៦.១៖** គំរូវេជ្ជសាស្ត្រនៃពិការភាព

### ២.២. គំរូសង្គមនៃពិការភាព

ផ្ទុយទៅវិញនៅក្នុង**គំរូសង្គម** មូលហេតុនៃពិការភាពត្រូវបានគេចាត់ទុកថា ស្ថិតនៅក្នុងបរិយាកាសសង្គម។ ឧទាហរណ៍ ទោះបីជាមនុស្សពិការជើងដោយសារជាន់គ្រាប់មីនមិនទាន់ផ្ទុះក៏ដោយ ក៏ពួកគេនៅតែអាចបន្លាស់ទីបានដោយការពាក់អវយវៈសិប្បនិម្មិត ឬប្រើរទេះរុញដៃរ។ ក្នុងករណីបែបនេះ ការពិការជើងគ្មានទំនាក់ទំនងដោយផ្ទាល់ទៅនឹងការថយចុះសមត្ថភាព ឬទទួលរងនូវគុណវិបត្តិសង្គមទេ។

ទោះជាយ៉ាងណាក៏ដោយ តើមានអ្វីកើតឡើងប្រសិនបើសង្គមកម្ពុជាមិនអាចផ្គត់ផ្គង់ជើងសិប្បនិម្មិត ឬរទេះរុញបានទេនោះ? ឬប្រសិនបើផ្លូវថ្នល់ លំនៅដ្ឋាន និងបរិយាកាសកន្លែងធ្វើការមិនត្រូវបានផ្លាស់ប្តូរដើម្បីផ្តល់ភាពងាយស្រួល

ដល់រទេះរុញ? ក្នុងករណីបែបនេះ បរិយាកាសសង្គមគឺជាមូលហេតុនៃពិការភាព។ នោះគឺជាគោលគំនិតជាមូលដ្ឋាននៃគំរូសង្គម។

សូមក្រឡេកមើលរូបភាពខាងក្រោម ហើយពិចារណាកន្លែងដែលមានពិការភាព (**រូបទី ១៦.២**)។



**រូបទី ១៦.២៖** មនុស្សមានពិការភាពនៅលើរទេះរុញនៅទល់មុខកាំជណ្ដើរ។ តើពិការភាពស្ថិតនៅត្រង់ណា?

## ២.៣. ចំណាត់ថ្នាក់ជាអន្តរជាតិលើការបំពេញមុខងារ ពិការភាព និងសុខភាព ជាគំរូសមាហរណកម្មនៃពិការភាព

**អាយ ស៊ី អេហ្វ** (ICF) គឺជាការចាត់ថ្នាក់លើសុខភាព និងលក្ខខណ្ឌនានាពាក់ព័ន្ធនឹងសុខភាពសម្រាប់កុមារ និងមនុស្សពេញវ័យដែលបានបង្កើតដោយអង្គការសុខភាពពិភពលោក និងបានបោះពុម្ពផ្សាយក្នុងឆ្នាំ២០០១។

**គំរូសមាហរណកម្មនៃពិការភាព**គឺជាការប៉ុនប៉ងរួមបញ្ចូលគ្នា ឬយ៉ាងហោចណាស់ជាការផ្សំបញ្ចូលគ្នារវាងទស្សនៈផ្នែកវេជ្ជសាស្ត្រ និងសង្គម។[4] គំរូនេះធ្វើឱ្យជនមានពិការភាពមានតួនាទីខុសៗគ្នា «រួមទាំងតួនាទីជាពលរដ្ឋនិងជាអ្នកជំងឺក្នុងចំណោមតួនាទីជាច្រើនផ្សេងទៀត»។[4,5] ចំណុចសំខាន់ដែលត្រូវកត់សម្គាល់គឺគំរូនេះត្រូវបានបង្កើតឡើងដើម្បីអនុវត្តក្នុងលក្ខខណ្ឌណាមួយសម្រាប់មនុស្សគ្រប់រូបមិនមែនសម្រាប់អនុវត្តតែលើជនពិការប៉ុណ្ណោះទេ។

ដូចបានបង្ហាញក្នុង**រូបភាពទី ១៦.៣** គំរូអាយ ស៊ី អេហ្វ (ICF) ចាត់ទុកពិការភាពថាជាសភាពនៃការខូចមុខងារ ឬការរំខានដល់ជីវិតមនុស្សប្រចាំថ្ងៃ។ **ជីវិតប្រចាំថ្ងៃ**ត្រូវបានចែកជា ៣ផ្នែក គឺ **មុខងារ និងរចនាសម្ព័ន្ធនៃរាងកាយ និងផ្លូវចិត្ត សកម្មភាព** និង**ការចូលរួមក្នុងសង្គម**។ ឧទាហរណ៍ ការខូចមុខងារ ឬការរំខានដល់មុខងារនិងរចនាសម្ព័ន្ធនៃរាងកាយនិងផ្លូវចិត្ត មានន័យថា **ភាពចុះខ្សោយនៃរាងកាយ**ដែលបង្ហាញពីភាពមិនប្រក្រតីនៃមុខងារផ្លូវចិត្ត មុខងារសរសៃប្រសាទ មុខងារវិញ្ញាណដូចជា ការមើលឃើញនិងការស្ដាប់ឮ សរីរាង្គសំឡេង ប្រព័ន្ធរំលាយអាហារ និងឈាមរត់ ប្រព័ន្ធភាពស៊ាំ ប្រព័ន្ធអង់ដូគ្រីន ឬប្រព័ន្ធបន្តពូជជាដើម។ ដែនកំណត់នៃសកម្មភាពសំដៅទៅលើការលំបាកក្នុងការអនុវត្តសកម្មភាពដូចជា ការដើរ ការបរិភោគ ការដឹកជញ្ជូន ឬការរាប់លុយ។ ការដាក់កម្រិតលើការចូលរួមក្នុងសង្គមសំដៅទៅលើការដាក់កម្រិត/ការកំណត់ ឬកង្វះខាតក្នុងការចូលរួមនៅក្នុងវិស័យណាមួយនៃជីវិតដូចជា ការអប់រំ ការប្រកបការងារ ឬការកំសាន្តផ្សេងៗ។ ទំនាក់ទំនងរវាងលក្ខខណ្ឌសុខភាព សកម្មភាពប្រចាំថ្ងៃ និងកត្តាបរិស្ថាន ជាមួយនឹងកត្តាបុគ្គលត្រូវបានបង្ហាញដោយព្រួញសងខាងដែលបញ្ជាក់ពីអន្តរកម្មរបស់វា។[6]

ការខូចមុខងារទាំងបីប្រភេទនៃជីវិតប្រចាំថ្ងៃត្រូវបានជះឥទ្ធិពល និងរងផលប៉ះពាល់ដោយ**កត្តាបរិស្ថាន** (ឧទាហរណ៍ ផលិតផលនិងបច្ចេកវិទ្យា បរិស្ថានធម្មជាតិ និងការផ្លាស់ប្ដូរដែលបង្កើតឡើងដោយមនុស្សទៅលើបរិស្ថាន សេវាកម្ម ប្រព័ន្ធ និងគោលនយោបាយផ្សេងៗ) និង**កត្តាបុគ្គល** (ឧទាហរណ៍ អាយុ ភេទ ជាតិសាសន៍ ទស្សនវិស័យលើជីវិត និងរចនាបថជីវិត)។ ក្រៅពីនេះ រូបភាពខាងក្រោមនេះបង្ហាញថា មុខងារនៃជីវិតប្រចាំថ្ងៃមានទំនាក់ទំនងជាមួយ**លក្ខខណ្ឌផ្សេងៗនៃសុខភាព**ដូចជា ជំងឺ និងការរងរបួស។




ប្រភព៖ World Health Organization. How to use the ICF: A practical manual for using the International Classification of Functioning, Disability and Health (ICF). Exposure draft for comment. October 2013. Geneva: WHO.[3]

**រូបទី ១៦.៣៖** គំរូ ICF៖ អន្តរកម្មរវាងសមាសធាតុផ្សេងៗរបស់ ICF

## ៣ តើសង្គមកម្ពុជាមានទស្សនៈយ៉ាងណាចំពោះជំងឺ និងពិការភាព?

ជំងឺ និងពិការភាពអាចនាំឱ្យមាន**បុរេវិនិច្ឆ័យ ការមាក់ងាយ** និង**ការរើសអើង**។ ទោះជាយ៉ាងណានៅប្រទេសកម្ពុជា របាយការណ៍ថ្មីៗនេះផ្អែកលើការស្ទង់មតិរបស់**អ្នកផ្ទុកមេរោគអេដស៍**បង្ហាញពីលទ្ធផលមួយគួរឱ្យចាប់អារម្មណ៍។ ឧទាហរណ៍ ករណីនៃការរើសអើងការងារ ឬការបាត់បង់ប្រាក់ចំណូលដោយសារជំងឺអេដស៍បានធ្លាក់ចុះពី ៤៦% ក្នុងឆ្នាំ២០១០ មកត្រឹម ២% ក្នុងឆ្នាំ២០១៩ ។ អ្នកដែលទទួលរងការបៀតបៀនដោយពាក្យសំដីបានធ្លាក់ចុះពី ១៤% មកត្រឹម ៣% ក្នុងអំឡុងពេលដូចគ្នា។[7] ទោះជាយ៉ាងនេះក្តី របាយការណ៍ដដែលកត់សម្គាល់ថា ទោះបីជាមានការថយចុះនៃមាក់ងាយ និងការរើសអើងពីអ្នកដទៃក៏ដោយ «**ការមាក់ងាយចំពោះខ្លួនឯង**» (ដែលបណ្តាលមកពីការអៀនខ្មាស កំហុស និងការបន្ទោសខ្លួនឯង) មានការថយចុះតែបន្តិចបន្តួចប៉ុណ្ណោះ។

តើមានការផ្លាស់ប្តូរបែបនេះកើតឡើងនៅក្នុងប្រទេសកម្ពុជាដោយរបៀបណា និងដោយមូលហេតុអ្វី? តើបុរេវិនិច្ឆ័យ ការមាក់ងាយ និងការរើសអើងប្រភេទណា ដែលកើតមានលើប្រភេទជំងឺ និងពិការភាពប្រភេទដទៃទៀតដូចជា ជំងឺផ្លូវចិត្ត ពិការភ្នែក ឬបាត់បង់សមត្ថភាពស្តាប់ឮ?

## ៤ តម្រូវការការអប់រំពិសេសសម្រាប់កុមារពិការនៅប្រទេសកម្ពុជា

យោងតាមគោលនយោបាយស្តីពីការអប់រំសម្រាប់កុមារមានពិការភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា កុមារ ៦៨% នៃកុមារមានពិការភាពទាំងអស់រងគ្រោះពីបញ្ហាគំហើញ បញ្ហាសមត្ថភាពស្តាប់ឮ ឬបញ្ហានានាទាក់ទងនឹងបន្លាស់ទី។[8] ក្នុងក្រុមកុមារអាយុពី ៥-១៧ឆ្នាំ ក្នុងនោះមានក្មេងប្រុស ២,៦% និងក្មេងស្រី ២,៩% មិនបានចូលរៀនដោយសារពិការភាព។ ជាអកុសល ប្រទេសកម្ពុជាខ្វះអ្នកជំនាញផ្នែកការអប់រំកុមារមានពិការភាពដែលជាហេតុធ្វើឱ្យការដាក់ដំណើរការនៃ**ការអប់រំបរិយាបន្ន**គ្មានការវិវឌ្ឍដោយរលូននោះទេ។

ប្រការនេះបង្កើតឱ្យមានជាបញ្ហាប្រឈមក្នុងការធានាការអប់រំសម្រាប់កុមារមានពិការភាពតាមរយៈ**ក្របខ័ណ្ឌនៃសាលារៀនកុមារមេត្រី**ដែលត្រូវបានអនុម័តនៅក្នុងគោលនយោបាយ។ វត្ថុបំណងមួយនៃគោលនយោបាយនេះគឺដើម្បីលើកកម្ពស់ការយល់ដឹងអំពីស្ថានភាពរបស់ជនមានពិការភាពនៅក្នុងសហគមន៍ និងដើម្បីលើកកម្ពស់ការទទួលយកបុគ្គលទាំងនោះទៅក្នុងសង្គមក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។

### អត្ថបទដកស្រង់ ១៦.១៖ ការអប់រំបរិយាបន្នសម្រាប់កុមារ

*កុមារទាំងអស់មានសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពដោយផ្អែកលើគោលការណ៍ «ការអប់រំសម្រាប់ទាំងអស់គ្នា»។ ការធានាការអប់រំគឺជាគន្លឹះក្នុងការអភិវឌ្ឍប្រកបដោយចីរភាព សន្តិភាព និងស្ថិរភាពក្នុងចំណោមប្រទេសនានា នេះគឺជាបញ្ហាបន្ទាន់មួយ។ ទោះជាយ៉ាងណា ដោយសារតែមានលក្ខខណ្ឌផ្សេងៗមួយចំនួន មានកុមារខ្លះលំបាកក្នុងការទទួលបានការអប់រំហើយត្រូវបានគេផាត់ចេញពីការអប់រំ។ តើកុមារប្រភេទណាដែលត្រូវបានរារាំងពីសិទ្ធិទទួលបានការអប់រំ? ឧទាហរណ៍ កុមារមានពិការភាព ក្មេងស្រី កុមាររស់នៅតំបន់ដាច់ស្រយាល កុមាររស់តាមចិញ្ចើមផ្លូវ កុមារស៊ីឈ្នួលគេ កុមារក្នុងគ្រួសារក្រីក្រ និងកុមារដែលជាជនជាតិភាគតិចដែលកុមារទាំងនេះសុទ្ធតែមានតម្រូវការពិសេសសម្រាប់ការអប់រំ។ ការអប់រំបរិយាបន្នមិនត្រឹមតែរួមបញ្ចូលទាំងកុមារដែលមានតម្រូវការពិសេសទាំងនេះនៅក្នុងការអប់រំនៅសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែវាក៏ផ្លាស់ប្តូរសាលារៀនទាំងមូលដើម្បីឱ្យកុមារដែលមានចរិតលក្ខណៈចម្រុះអាចរៀនសូត្របានដូចៗគ្នា។*

ប្រភព៖

- Disability Action Council. Inclusive education training in Cambodia. *https://www.eenet.org.uk/resources/docs/cambodia.pdf*
- Education World Forum. The Darkar Framework For Action. UNESCO 2000. *https://sustainabledevelopment.un.org/content/documents/1681Dakar%20Framework%20for%20Action.pdf*

### អត្ថបទដកស្រង់ ១៦.២៖ សាលាកុមារមេត្រី

*រាល់ប្រព័ន្ធសង្គម និងភ្នាក់ងារទាំងឡាយដែលមានឥទ្ធិពលលើកុមារគួរតែផ្អែកលើគោលការណ៍នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ផ្អែកលើគោលការណ៍នេះ* ***អង្គការយូនីសេហ្វ (UNICEF)*** *បានបង្កើតក្របខ័ណ្ឌសាលាកុមារមេត្រីដែលត្រូវបានកំណត់ថាមានលក្ខណៈ «បរិយាបន្ន សុខភាពល្អ និងការការពារសម្រាប់កុមារទាំងអស់មានប្រសិទ្ធភាពជាមួយកុមារ និងពាក់ព័ន្ធជាមួយគ្រួសារ និងសហគមន៍ និងកុមារ»។*

ប្រភព៖ https://www.unicef.org/french/lifeskills/index_7260.html

### អត្ថបទដកស្រង់ ១៦.៣៖ តើយូនីសេហ្វគឺជាអ្វី?

*មូលនិធិកុមារនៃអង្គការសហប្រជាជាតិ (UNICEF) គឺជាអង្គការអន្តរជាតិមួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៤៦ ដើម្បីផ្តល់ជំនួយបន្ទាន់ដល់កុមារដែលរងគ្រោះក្រោយសង្គ្រាមលោកលើកទី ២។ បេសកកម្មរបស់អង្គការយូនីសេហ្វគឺដើម្បីជួយសង្គ្រោះជីវិតកុមារ ការពារសិទ្ធិ និងជួយឱ្យពួកគេបំពេញសក្តានុពលរបស់ពួកគេតាំងពីកុមារតូចរហូតដល់វ័យជំទង់។ បុគ្គលិករបស់អង្គការយូនីសេហ្វធ្វើការនៅតាមបណ្តារដ្ឋ និងប្រទេសជាង ១៩០ នៅទូទាំងពិភពលោក។*

ប្រភព៖

- https://www.unicef.org/
- https://www.unicef.org/eca/press-releases/unicef-commemorates-70-years

## លំហាត់សម្រាប់ការគិត និងការស្រាវជ្រាវបន្ថែម

[១៦-១] ចូរពិចារណាថា តើអ្វីទៅជាពិការភាព ហើយតើលក្ខខណ្ឌដែលបង្កឱ្យមានពិការភាពមានន័យដូចម្ដេចចំពោះអ្នក។

[១៦-២] ដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក ចូរពិចារណាថា តើមូលហេតុអ្វីខ្លះដែលតម្រូវឱ្យកម្មវិធីអប់រំពិសេសត្រូវផ្ដល់ជូនចំពោះកុមារមានពិការភាព។

[១៦-៣] ពិនិត្យមើលទស្សនៈរបស់សង្គមកម្ពុជាចំពោះពិការភាព។ ចូរសង្កេតមើលថា តើសង្គមកម្ពុជាមានទស្សនៈបែបណាចំពោះពិការភាព។

## ឯកសារយោង៖


1. World Health Organization. International Classification of Impairments, Disabilities, and Handicaps. 1980. Geneva: WHO https://apps.who.int/iris/bitstream/handle/10665/41003/9241541261_eng.pdf?sequence=1&isAllowed=y
2. World Health Organization. Towards a Common Language for Functioning, Disability and Health ICF. 2002. Geneva: WHO https://www.who.int/classifications/icf/icfbeginnersguide.pdf?ua=1
3. World Health Organization. How to use the ICF: A practical manual for using the International Classification of Functioning, Disability and Health (ICF). Exposure draft for comment. October 2013. Geneva: WHO https://www.who.int/classifications/drafticfpracticalmanual2.pdf?ua=1
4. Anderberg P. Making both ends meet. Disability Studies Quarterly. 25:3, 2005. https://dsq-sds.org/article/view/585/762#:~:text=The%20integrated%20model%20of%20disability,%22%20 (Seelman%2C%202003).
5. Seelman, K. D. Trends in rehabilitation and disability: transition from a medical model to an integrative model. National Rehabilitation Conference Keynote. Tokorozawa, Japan: National Center for Persons with Disabilities. 2003. https://www.normanet.ne.jp/~rehab/2003/seelman.pdf
6. Fitzgerald D. People living with disabilities. https://slideplayer.com/slide/13222050/
7. Cambodia sees decline in stigma, discrimination against HIV carriers: new survey. Asia & Pacific. 2019-08-28. http://www.xinhuanet.com/english/2019-08/28/c_138344792.htm
8. Ministry of Education, Youth and Sport. Policy on Education for Children with disabilities. http://www.moeys.gov.kh/en/press-releases/policy-on-education-for-children-with-disabilities.html#.XvB1EWj7SUk